# មាតាបិតាក៏រាប់ផងដែរ

## ជួយកូនរបស់លោកអ្នកនៅក្នុង - ការរាប់

ការពិសោធន៍ដំបូងដែលកុមារមានជាមួយលេខគឺ "ការរាប់"។ ការរាប់ចាប់ផ្តើមដូចគ្នានឹងការរៀនលំនាំនៃពាក្យយ៉ាងនោះដែរ គឺដូចគ្នានឹងចំរៀងបំពេរកូន។ ក្នុងកាលដែលកុមារចេះរាប់ហើយ នោះគេចាប់ផ្តើមប្រដូចពាក្យទៅនឹងចំនួនរបស់។

## តើកុមាររៀនចេះរាប់ ហើយប្រើលេខដោយរបៀបណា?

កុមាររៀនចេះលំនាំនៃការរាប់ពាក្យដោយធ្វើដដែលៗ។ ជាដំបូងលំនាំនេះអាចមានចន្លោះខ្វះដែលកុមាររំលងចោលលេខដែលមាននៅក្នុងលំដាប់នោះ ឬកុមារអាចបង្កើតពាក្យមួយចំនួន។ នេះគឺជាការធម្មតាទេដែលឮសូរកុមារនិយាយថា ម្ភៃដប់បន្ទាប់ពីគេបានរាប់ម្ភៃប្រាំបួនរួចហើយ។

ទោះបីជាយ៉ាងណាក្តី ការចងចាំពាក្យសំរាប់លេខនីមួយៗទៅតាមលំដាប់ត្រឹមត្រូវគឺជាផ្នែកនៃដំណើរនៃការរាប់ប៉ុណ្ណោះ។ ដើម្បី "រាប់" កុមារត្រូវការផ្គូរផ្គងដោយនិយាយពាក្យលេខ ជាមួយនឹងចំនួននៃ "របស់" ត្រឹមត្រូវ។

កុមារគួរតែបានទទួលឱកាសយ៉ាងច្រើនដើម្បីហាត់រៀន ហើយរុករកក្រុមរាប់ ក៏ដូចគ្នានឹងការបង្កើតក្រុមផងដែរ។ កុមារក៏ត្រូវការរៀនសម្គាល់ និងដាក់ឈ្មោះលេខផងដែរ។



# មាតាបិតាក៏រាប់ផងដែរ

## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?



- រាប់ចំនួនឡេវអាវជាមួយកូនរបស់លោកអ្នក នៅពេលលោកអ្នកដេរដាក់ឡេវអាវប៉ាក់ ឬអាវដៃវែង។
- លើកទឹកចិត្តឲ្យកូនរបស់លោកអ្នករាប់ចំនួនដង្កៀបហាលខោអាវប្រើសំរាប់គៀបសម្លៀកបំពាក់ហាល។
- រាប់ចំនួនជំហានចាប់ពីមាត់ទ្វារមុខផ្ទះ ទៅប្រអប់សំបុត្រ។
- រាប់ចំនួនស៊ុតដែលមាននៅក្នុងប្រអប់ ហើយរាប់ម្តងទៀតបន្ទាប់ពីបានយកខ្លះចេញពីប្រអប់។
- រាប់ចំនួនប៉ុន្មានដងដែលលោកអ្នក និងកូនរបស់លោកអ្នកអាចបោះបាល់ដាក់គ្នាទៅវិញទៅមកដោយមិនបានធ្លាក់។
- អានហើយ និយាយអំពីរឿង និងពាក្យជូនគ្នាដែលប្រើលេខ។
- ច្រៀងចំរៀង និងចំរៀងបំពេរកូនដែលមានលេខដូចជា Five Little Ducks (សត្វកូនទាប្រាំ) និង Baa Baa Black Sheep (បាបាចៀមខ្មៅ)
- ឲ្យកូនរបស់លោកអ្នករាប់ឲ្យបានវែងដែលអាចធ្វើទៅបានរួច ហើយលើកទឹកចិត្តកូនរបស់លោកអ្នកឲ្យចូលរួមជាមួយលោកអ្នក ក្នុងកាលដែលលោកអ្នករាប់បន្ត។
- ប្រាប់ឲ្យកូនរបស់លោកអ្នកចាប់រាប់ពីលេខណាមួយ ក្រៅពីលេខមួយ។ ការនេះនឹងជួយគេនៅពេលណាគេត្រូវការបូកលេខពីរក្រុមបញ្ចូលគ្នា ហើយអាចចាប់ផ្តើមរាប់ពីក្រុមដែលធំជាង។
- ប្រាប់ឲ្យកូនរបស់លោកអ្នកនិយាយប្រាប់លោកអ្នកនូវលេខមួយ ដែលនៅពីមុនឬបន្ទាប់លេខមួយទៀត។ តើកូនមានអាយុប៉ុន្មាននៅឆ្នាំក្រោយនេះ? តើកូនមានអាយុប៉ុន្មានកាលពីឆ្នាំកន្លងទៅនេះ?
- ប្រាប់ឲ្យកូនរបស់លោកអ្នកចែកចានពែង ឬសម ស្លាបព្រាសំរាប់មនុស្សម្នាក់ៗនៅពេលរៀបចំតុបាយ។

# មាតាបិតាក៏រាប់ផងដែរ



- លេងល្បែងទាំងឡាយដូចជា Dominoes (ដូមីណូ), Snakes and ladders (ពស់ និងជណ្តើរ) ល្បែងសន្លឹកបៀរ ឬល្បែងពីលើបន្ទះក្តារដែលមានគ្រាប់កូនឡុកឡាក់ និងរាងចំណុចខ្លះៗ។ នេះនឹងជួយឲ្យកូនរបស់លោកអ្នករៀនចំណាំរូបរាង ហើយចេះរាប់។ ប្តូរគ្រាប់កូនឡុកឡាក់ទៅមួយទៀតដែលមានបង្ហាញជាលេខដើម្បីជួយឲ្យកូនរបស់លោកអ្នកចេះអាន និងចំណាំលេខ។
- ប្រមូលសំបកលាសរួចដាក់ទៅតាមក្រុម។ រាប់ចំនួនសំបកលាសដែលមាននៅក្នុងក្រុមនីមួយៗ។
- សម្លឹងមើលរួចអានលេខផ្ទាកឡាន និងសញ្ញាផ្លូវថ្នល់។
- ប្រាប់ឲ្យកូនរបស់លោកអ្នករាប់ចំនួនដុំ នៅពេលលោកអ្នកកាត់ដុំម្ហូបដូចជានំផាយ នំប៉ាវ ផ្លែឈើ ឬនំប៉ុងសៀនវិច។
- យកក្រដាសរឹងរៀបចំធ្វើជាចំការសត្វ។ រាប់ចំនួនសត្វជ័រជាមួយកូនរបស់លោកអ្នក នៅពេលគេដាក់សត្វជ័រនៅទៅក្នុងចំការនីមួយៗ។ សួរសំណួរទាំងឡាយដូចជា:តើចំការណាមួយមានសត្វជ័រច្រើនជាងគេ? បន្ទាប់ពីបានដាក់សត្វជ័រខ្លះចូលទៅក្នុងចំការ ហើយបញ្ឈប់ រួចចាប់រាប់បន្តទៀតនៅពេលលោកអ្នកដាក់បន្ថែមទៀត។
- ជួយកូនលោកអ្នកឲ្យចេះចងចាំលេខទូរស័ព្ទរបស់លោកអ្នក ហើយចុចលេខទូរស័ព្ទឲ្យបានត្រឹមត្រូវ។